# អ នុ ស្ស រ ណៈ

## រវាង

## អង្គការក្រៅរដ្ឋាភិបាលបរទេស

## INTERNATIONAL JUSTICE MISSION ( IJM )

## និង

## រាជរដ្ឋាភិបាលកម្ពុជា

*****

## ផ្នែកទី មួយ

## បុព្វកថា

"ដោយយល់ថា" រាជរដ្ឋាភិបាលកម្ពុជា មានបំណងអោយអង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** ធ្វើសកម្មភាពមនុស្សធម៌ដើម្បីសុខុមាលភាពសង្គម និងផលប្រយោជន៍សាធារណៈ ដោយធ្វើការសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជា និង

"ដោយយល់ថា" អង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** មានទីស្នាក់ការអន្តរជាតិនៅក្រៅប្រទេសនៅសហរដ្ឋអាមេរិក និងមានការិយាល័យកណ្តាលនៅភ្នំពេញ ជាអង្គការមនុស្សធម៌ មិនធ្វើអាជីវកម្មយកចំណេញដូចមានចែងនៅក្នុងឯកសារនៃសេចក្តីប្រកាសបេសកកម្ម ទិសដៅ និងកម្មវិធីរបស់អង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** ។

"ដោយយល់ថា" អង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** យល់ព្រមអនុវត្តតាមវិធាននៃច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ស្ថិតក្នុងគោលបំណងនៃអនុស្សរណៈនេះ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** បានព្រមព្រៀងគ្នាដូចតទៅ :

# ផ្នែកទីពីរ

## ភារកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាមានភារកិច្ចដូចតទៅ :

**ប្រការ ១ :**

ទទួលស្គាល់ថាអង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** ដែលបានអនុញ្ញាតឱ្យបើកការិយាល័យនៅភ្នំពេញ ឬតាមខេត្តក្រុងនានា ដើម្បីធ្វើសកម្មភាពមនុស្សធម៌ និងអនុវត្តគំរោងការដែលទទួលការអនុញ្ញាតនៅក្នុងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិទាំងឡាយនៃព្រះរាជណាចក្រកម្ពុជា និងបំពេញភារកិច្ច ស្របតាមអនុស្សរណៈនេះ ។

**ប្រការ ២ :**

អនុញ្ញាតឱ្យអង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** អនុវត្តការងារមនុស្សធម៌ នៅទីកន្លែងផ្សេងៗទៀត ឬតាមទីរួមខេត្ត ដោយមានការយល់ព្រមត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា ដោយផ្អែកលើអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា និងសមត្ថភាពជំនាញ និងថវិកា ដែលអង្គការក្រៅរដ្ឋាភិបាលបរទេសនោះមាន ។

**ប្រការ ៣ :**

ផ្តល់ជូននូវលិខិតសំគាល់ខ្លួនដល់បុគ្គលិកបរទេស ដែលត្រូវទទួលបាននូវលិខិតអនុញ្ញាតឱ្យធ្វើការងារពីក្រសួងទទួលបន្ទុកវិស័យការងារ តាមច្បាប់កំណត់របស់ព្រះរាជាណាចក្រកម្ពុជា ។ ពាក្យថា "បុគ្គលិកបរទេស" គឺរាប់បញ្ចូលទាំងអ្នកតំណាងអង្គការ បុគ្គលិកបរទេស អ្នកជំនាញ ទីប្រឹក្សា និងអ្នកម៉ៅការបរទេសទាំងអស់ ដែលត្រូវបានជ្រើសរើសអោយបំពេញមុខងារពិសេសណាមួយ យោងតាមទេពកោសល្យជាក់ស្តែង និងជំនាញច្បាស់លាស់ ។

**ប្រការ ៤ :**

អនុញ្ញាតឱ្យស្នាក់នៅបណ្ដោះអាសន្ននៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះបុគ្គលិកបរទេស នៃអង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** កាលបើពេលវេលានៃការងារនោះត្រូវបំពេញលើសពីបីខែ ហើយការអនុញ្ញាតនោះត្រូវធ្វើឡើងទៅតាមការកំណត់នៃច្បាប់ និងបទបញ្ញត្តិផ្សេងៗ នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៥ :**

អនុញ្ញាតឱ្យអង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** សហការផ្ទាល់ជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងធ្វើគំរោងផែនការ ការអនុវត្តន៍ ការត្រួតពិនិត្យ និងការបូកសរុបវាយតំលៃលើគំរោងការ ។

**ប្រការ ៦ :**

ជូនពត៌មានដល់អង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** នូវច្បាប់ បទបញ្ញត្តិ សេចក្ដីសំរេច និងបទកំណត់ថ្មីៗឯទៀត ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងអង្គការក្រៅរដ្ឋាភិបាល ។

**ប្រការ ៧ :**

អនុញ្ញាតឱ្យអង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** ជួលដី ជួលផ្ទះ សាងសង់ ឬជួលការិយាល័យ និងអាគារដែលចាំបាច់សំរាប់ធ្វើសកម្មភាពមនុស្សធម៌ សមស្របតាមច្បាប់និងបទបញ្ញត្តិក្នុងស្រុក និងជ្រើសរើសបុគ្គលិកកម្ពុជា ដោយគោរពតាមបទបញ្ញត្តិច្បាប់ការងារ ។

**ប្រការ ៨ :**

អនុញ្ញាតការនាំចូលនូវសំភារៈប្រើប្រាស់ គ្រឿងបរិក្ខារ គ្រឿងចក្រ ដែលបានកំណត់ក្នុងគំរោងការដែលទទួលការអនុញ្ញាត និងស្របតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ។ ពន្ធអាករលើការនាំចូលទាំងនោះជាបន្ទុករបស់រដ្ឋ ។

ចំពោះសំភារៈប្រើប្រាស់ផ្ទាល់ខ្លួន និងយានយន្តត្រូវបានអនុញ្ញាតឱ្យនាំចូលតាមរបបនាំចូលបណ្ដោះអាសន្ន ។

**ប្រការ ៩ :**

យល់ព្រមថាអង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** និងបុគ្គលិកបរទេសរបស់ខ្លួន នឹងត្រូវបានទទួលនូវគុណប្រយោជន៍ដូចអង្គការក្រៅរដ្ឋាភិបាលបរទេស និងបុគ្គលិកបរទេសដទៃទៀត ដែលបានអនុញ្ញាតអោយធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្នុងករណី ដែលមានចែងក្នុងប្រការទី ១៩ ។

**ប្រការ ១០ :**

ផ្តល់ទិដ្ឋាការចាំបាច់ដោយឥតគិតថ្លៃ ដោយស្ថានបេសកកម្មការទូតកម្ពុជាប្រចាំនៅបរទេសចំពោះបុគ្គលិកបរទេស រួមទាំងសមាជិកគ្រួសាររបស់គេសំរាប់រយៈពេល១ខែដំបូងនៃការស្នាក់នៅកម្ពុជា។ រាល់ការបន្តទិដ្ឋាការជាបន្តបន្ទាប់មកទៀតនឹងមិនត្រូវគិតតំលៃឡើយ ។ សមាជិកគ្រួសាររួមមាន ប្តី ប្រពន្ធ កូន និងឪពុក ម្តាយ។

## ផ្នែកទី បី

## ភារកិច្ចរបស់អង្គការក្រៅរដ្ឋាភិបាលបរទេស

## INTERNATIONAL JUSTICE MISSION

អង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** មានភារកិច្ចដូចតទៅ :

**ប្រការ ១១ :**

គោរពទាំងស្រុងនូវច្បាប់ និងបទបញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា និងមិនអនុញ្ញាតឱ្យបុគ្គលិករបស់ខ្លួនចូលរួមក្នុងសកម្មភាពទាំងឡាយណា ដែលអាចប៉ះពាល់ដល់សន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ជាតិ ប្រពៃណី ទំនៀមទំលាប់ជាតិរបស់សង្គមកម្ពុជា។

**ប្រការ ១២ :**

អនុវត្តនូវសកម្មភាពទាំងឡាយ និងប្រតិបត្តិនូវកម្មវិធីជំនួយក្នុងប្រទេសកម្ពុជា តាមគំរិតនៃបុគ្គលិក ធនធាន និងថវិកា ដូចបានចែងយ៉ាងលំអិតក្នុងឧបសម្ព័ន្ធនៃអនុស្សរណៈនេះ។

**ប្រការ ១៣ :**

ចូលរួមតែក្នុងប្រភេទសកម្មភាពណាដើម្បីបំរើសុខុមាលភាពសង្គម និងផលប្រយោជន៍សាធារណៈ ដែលបានទទួលការអនុញ្ញាត ។ មិនធ្វើអាជីវកម្មយកចំណេញ មិនចូលរួមគ្រប់សកម្មភាពនយោបាយដោយប្រកាន់ខ្ជាប់នូវទិសដៅមនុស្សធម៌និងអភិវឌ្ឍន៍សង្គមតែប៉ុណ្ណោះ។ រាយការណ៍ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរយៈពេលបីខែម្តងដោយពិពណ៌នាលំអិតពីសកម្មភាព ក្នុងផែនការនៃការហ៊ឹកហាត់ការអនុវត្តន៍គំរោង ឬកម្មវិធីរបស់អង្គការ ។

**ប្រការ ១៤ :**

បើកគណនីនៅធនាគារណាមួយ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ហើយធានាថាប្រាក់ចំណាយសំរាប់ផ្នែករដ្ឋបាលដែលគិតជាមធ្យមមិនត្រូវលើសពី ២៥ ភាគរយនៃថវិកាសរុប ព្រមទាំងត្រូវផ្តល់របាយការណ៍ជារៀងរាល់ឆ្នាំនូវតារាងតុល្យការគណនេយ្យលទ្ធផល ឬគណនេយ្យ ចំណូល ចំណាយ ព្រមទាំងឯកសារផ្សេងៗ ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺត ៩០ថ្ងៃ ក្រោយថ្ងៃបិទការិយបរិច្ឆេទគណនេយ្យរបស់អង្គការ ឬក្រោយថ្ងៃបិទការិយ បរិច្ឆេទឆ្នាំថវិកានៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ១៥ :**

ផ្តល់ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នូវបញ្ជីឈ្មោះថ្មីៗនៃបុគ្គលិកបរទេស និងកិច្ចសន្យាការងារព្រមទាំងជូនដំណឹងជាបន្ទាន់រាល់ការផ្លាស់ប្តូររាប់ទាំងការផ្លាស់ប្តូរអាស័យដ្ឋាន នៃការិយាល័យ កណ្តាល ឬសាខារបស់ខ្លួននៅកម្ពុជា ។

បញ្ជីឈ្មោះត្រូវរាប់បញ្ចូលពតិមានដូចតទៅ :

១. ឈ្មោះ (នាម និង គោត្តនាម)

២. សញ្ជាតិ

៣. លេខលិខិតឆ្លងដែន ឬលេខអត្តសញ្ញាណប័ណ្ណ ឬលេខឯកសារផ្សេងទៀតដែលមានតំលៃស្មើគ្នា ។

៤. មុខនាទីក្នុងអង្គការក្រៅរដ្ឋាភិបាល

៥. រយៈពេលនៃកិច្ចសន្យាការងារ- លិខិតអនុញ្ញាតឱ្យធ្វើការងារ

៦. ឈ្មោះសមាជិកគ្រួសារផ្ទាល់ដែលនៅក្នុងបន្ទុក និង

៧. អាស័យដ្ឋាននៅកម្ពុជា

ផ្តល់ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នូវបញ្ជីឈ្មោះ និងតួនាទីបុគ្គលិកក្នុងស្រុក ។

**ប្រការ ១៦ :**

ប្រើប្រាស់បុគ្គលិកកម្ពុជាអោយបានច្រើន ដោយគោរពច្បាប់ការងារ និងខិតខំកាត់បន្ថយចំនួនបុគ្គលិកបរទេសឱ្យនៅតិចបំផុតដែលអាចធ្វើទៅបានក្នុងរាល់គំរោង ឬកម្មវិធី ហើយបញ្ជាក់នូវផែនការផ្ទេរទេពកោសល្យ និងជំនាញដល់បុគ្គលិកកម្ពុជាឱ្យបានច្បាស់លាស់ ។

**ប្រការ ១៧ :**

ចៀសវាងការជ្រើសរើសអ្នកទេសចរណ៍ ឬជនបរទេសអន្តោប្រវេសន្តខុសច្បាប់ឱ្យធ្វើការទោះបំពេញការងារអ្វីក៏ដោយ។ បុគ្គលិកបរទេសត្រូវមានលិខិតអនុញ្ញាតអោយធ្វើការងារពីក្រសួងទទួលបន្ទុកវិស័យការងារនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ១៨ :**

បំពេញការងារដោយពិគ្រោះយោបល់ និងសហការឱ្យបានជិតស្និទ្ធជាមួយស្ថាប័នរដ្ឋាភិបាលដែលជាដៃគូនិងអាជ្ញាធរមូលដ្ឋាន ដើម្បីអនុវត្តនូវគំរោង ឬកម្មវិធីនានា។ ជាពិសេសត្រូវមានការជូនដំណឹងទៅដៃគូនៅពេលចាត់តាំងបុគ្គលិកជំនាញឱ្យទៅធ្វើការនៅការដ្ឋាន ឬក៏ស្នើសុំពន្យារពេលទិដ្ឋាការសំរាប់បុគ្គលិកជំនាញដើម្បីបំពេញការងារ ។

**ប្រការ ១៩ :**

យល់ព្រមថា បុគ្គលិកក្នុងស្រុក និងបុគ្គលិកបរទេសត្រូវដាក់ឱ្យស្ថិតនៅក្រោមបទបញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស និងពន្ធអាករផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានការសំរេចផ្សេងរបស់រាជរដ្ឋាភិបាល។

អង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** យល់ព្រមគោរពកាតព្វកិច្ចសារពើពន្ធស្របទៅតាមច្បាប់និងបទបញ្ញត្តិនានាស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី បួន

## អវសានប្បញ្ញត្តិ

**ប្រការ ២០ :**

នាយកអង្គការក្រៅរដ្ឋាភិបាល ឬតំណាងប្រចាំប្រទេសកម្ពុជា ឬតំណាងផ្លូវការផ្សេងទៀតទទួលសិទ្ធិពីអង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** ត្រូវបានទទួលស្គាល់ឱ្យធ្វើសកម្មភាពក្នុងនាមអង្គការជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ក្រោយពេលចុះហត្ថលេខាលើអនុស្សរណៈនេះ ។

**ប្រការ ២១ :**

អង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** មានសិទ្ធិផ្អាកសកម្មភាពរបស់ខ្លួន បន្ទាប់ពីបានជូនដំណឹងជាលិខិតអនុសិទ្ធិដល់រាជរដ្ឋាភិបាលកម្ពុជាចំនួន ៦០ ថ្ងៃមុន ។ អង្គការនេះ អាចចាប់ផ្តើមធ្វើការឡើងវិញបាន ដោយគ្រាន់តែជូនដំណឹងជាលិខិតអនុសិទ្ធិទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិតែប៉ុណ្ណោះ ។

**ប្រការ ២២ :**

រាជរដ្ឋាភិបាលកម្ពុជាអាចបញ្ចប់អនុស្សរណៈនេះ បន្ទាប់ពីមានការជូនដំណឹងជាលិខិតអនុសិទ្ធិបញ្ជាក់ដ៏ត្រឹមត្រូវដល់អង្គការក្រៅរដ្ឋាភិបាលបរទេស **INTERNATIONAL JUSTICE MISSION** ក្នុងករណីអង្គការបានរំលោភលើអនុស្សរណៈ ។ បញ្ឈប់ផ្តល់ការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នដល់បុគ្គលិកបរទេស ប្រសិនបើមានការរំលោភបំពានលើអនុស្សរណៈនេះ។

**ប្រការ ២៣ :**

រាល់វិវាទរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាល **INTERNATIONAL JUSTICE MISSION** ពាក់ព័ន្ធនឹងការអនុវត្តន៍អនុស្សរណៈនេះ ត្រូវដោះស្រាយតាមរយៈការចរចាផ្ទាល់រវាងភាគីទាំងពីរដោយសុទ្ធចិត្ត ។

**<u>ប្រការ ២៤</u> :**

អនុស្សរណៈនេះអាចបញ្ចប់បានដោយភាគីណាមួយ បន្ទាប់ពីបានជូនដំណឹងជាលិខិតអនុសិទ្ធិ ក្នុងរយៈពេល ៦០ថ្ងៃ ផ្ញើជូនភាគីម្ខាងទៀត ។

**<u>ប្រការ ២៥</u> :**

អនុស្សរណៈនេះនឹងចូលជាធរមានចាប់ពីពេលចុះហត្ថលេខាដោយភាគីទាំងពីរ និងមានសុពលភាពសំរាប់រយៈពេល ៣ឆ្នាំ និងអាចបន្តបានទៀត ដោយការយល់ព្រមពីភាគីទាំងពីរ ។

**<u>ប្រការ ២៦</u> :**

អនុស្សរណៈនេះធ្វើជាពីរច្បាប់ដើម ជាភាសាខ្មែរ និងអង់គ្លេស ដោយអត្ថបទទាំងពីរមានតំលៃស្មើគ្នា ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៣

**ជូសមុខអង្គការ INTERNATIONAL JUSTICE MISSION**

**GARY HAUGEN**

**PRESIDENT & CEO**

**IJM**

**ជូសមុខរដ្ឋាភិបាល**

**ធីវ ចំរើន**

**រដ្ឋលេខាធិការ**

# ខ្លឹមសារគន្លងនៃអនុស្សរណៈ

- <u>អង្គការក្រៅរដ្ឋាភិបាល</u> - ជាអង្គការដែលបង្កើតឡើងដោយបុគ្គល ឬ ក្រុមណាមួយដែលធ្វើសកម្មភាព មនុស្សធម៌ អភិវឌ្ឍន៍សង្គម ដើម្បីសុខុមាលភាពសង្គម និងផលប្រយោជន៍សាធារណៈ ដោយមិនធ្វើអាជីវកម្មយកចំណេញ ។ អង្គការក្រៅរដ្ឋាភិបាលមិនធ្វើសកម្មភាពបំរើគណៈបក្សនយោបាយ ។

- <u>ចំណាយរដ្ឋបាល</u> - ជាការចំណាយលើដំណើរការងាររដ្ឋបាល និងប្រាក់បៀវត្សបុគ្គលិករដ្ឋបាល និងនាយក ។

- <u>បុគ្គលិកជំនាញ</u> - ជាអ្នកជំនាញការបច្ចេកទេស និង ទីប្រឹក្សាបច្ចេកទេស ។

- <u>ជនអន្តោប្រវេសន៍</u> - ជាជនបរទេសដែលមកដល់កម្ពុជាដោយស្របច្បាប់ដើម្បីស្នាក់នៅរយៈពេលយូរ ឬ ដើម្បីប្រកបវិជ្ជាជីវៈ ឬ ធ្វើសកម្មភាពផ្សេងៗទាក់ទងនឹង ឧស្សាហកម្ម សេវា ឬ កសិកម្ម ។

# អនុស្សរណៈនៃការយោគយល់គ្នា
# រវាង
# អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និង ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា
# ស្តីពី
# ការចូលរួមសកម្មភាពមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជា

## ផ្នែកទី១
## បុព្វកថា

<u>ដោយហេតុថា:</u> ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា បានសម្តែងនូវបំណងប្រាថ្នា ដូចមានចែងក្នុងអនុស្សរណៈនៃការយោគយល់គ្នានេះថា អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ បានរួមចំណែកធ្វើការងារមនុស្សធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសុខុមាលភាពសង្គម និង ប្រយោជន៍សាធារណៈតាមរយៈកិច្ចសហប្រតិបត្តិការទៅវិញទៅមក ហើយនិង

<u>ដោយហេតុថា:</u> អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និង ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវសហការគ្នា ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសលើស្ត្រីនិងកុមារ ។

<u>ដោយហេតុថា:</u> ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ពិសេស លើស្ត្រីនិងកុមារ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងក្រសួងមហាផ្ទៃ តាមរយៈអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជាដោយផ្ទាល់សហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន ដើម្បីបន្តចូលរួមសកម្មភាពមនុស្សធម៌ដូចខាងក្រោម ៖

### ១. ការប្រមូលនិងការផ្តល់ព័ត៌មានសម្ងាត់

- អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា ដើម្បីស៊ើបអង្កេត ប្រមូលព័ត៌មាន ភស្តុតាងនៃសកម្មភាព ដែលពាក់ព័ន្ធអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅតាមបណ្តារមណីយដ្ឋាន និង ទីកន្លែងផ្សេងទៀតដែលសង្ស័យថាមានស្ត្រីនិងកុមារត្រូវបានជួញដូរដើម្បីធ្វើអាជីវកម្មផ្លូវភេទ ។
- អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវមានរបាយការណ៍ និងភស្តុតាងលម្អិតដែលប្រមូលបានជូននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នូវសកម្មភាពល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស ។
- អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវបង្ហាញទីតាំង និងអត្តសញ្ញាណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**២. ការធ្វើអន្តរាគមន៍និងការសង្គ្រោះ**

- អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយនគរបាលជាតិកម្ពុជា ដើម្បីសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងធានាដល់ការចាប់ខ្លួនជនប្រព្រឹត្តបទល្មើស បញ្ជូនទៅតុលាការ ផ្តន្ទាទោសតាមច្បាប់ ។
- អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវសហការជាមួយនគរបាលជាតិកម្ពុជា ក្នុងការផ្តល់សេវាកម្មផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដើម្បីនាំជនល្មើស ផ្តន្ទាទោសតាមច្បាប់ ។

**៣. ការសម្របសម្រួលក្រោយពេលសង្គ្រោះ**

- អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវសហការដឹកជញ្ជូនជនរងគ្រោះចេញពីកន្លែងកើតហេតុមកកាន់ទីស្នាក់ការនគរបាល ដើម្បីធ្វើការសាកសួរព័ត៌មាន និងដឹកជញ្ជូនបន្តទៅកាន់មណ្ឌលគ្រប់គ្រងថែទាំ និងពីមណ្ឌលគ្រប់គ្រងថែទាំ ទៅតុលាការដើម្បីដំណើរការរឿងក្តី ។
- អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវសម្របសម្រួលជាមួយមន្ត្រីនគរបាលជាតិកម្ពុជា និងមន្ត្រីរដ្ឋាភិបាលមានសមត្ថកិច្ចផ្សេងទៀត ដើម្បីផ្តល់នូវការគាំទ្រដល់ជនរងគ្រោះ ជាពិសេសអនីតិជន បន្ទាប់ពីមានការជួយសង្គ្រោះ ។

**៤. ការបណ្តុះបណ្តាលនគរបាល**

- អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវសហការផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នូវបច្ចេកទេសស៊ើបអង្កេត និង ច្បាប់ពាក់ព័ន្ធតាមសំណូមពរជាក់ស្តែងរបស់ក្រសួងមហាផ្ទៃ ។

<u>ដោយហេតុថា:</u> អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវគោរពតាមច្បាប់ និង បទបញ្ញាផ្សេងៗ របស់ព្រះរាជាណាចក្រកម្ពុជា ហើយនិងធ្វើកិច្ចសហប្រតិបត្តិការឲ្យកាន់តែជិតស្និទ្ធថែមទៀត រវាងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ជាមួយនឹងក្រសួងមហាផ្ទៃ ដើម្បីសម្រេចបាននូវគោលដៅមនុស្សធម៌របស់ខ្លួន ។

**ក្រសួងមហាផ្ទៃ និង អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** បានព្រមព្រៀងដូចខាងក្រោម ៖

## ផ្នែកទី២
## ការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃ ត្រូវទទួលខុសត្រូវដូចខាងក្រោម ៖

**មាត្រា១ ៖** ទទួលស្គាល់ព័ត៌មាន និង ភស្តុតាងដែលប្រមូលបាន ទាក់ទងនឹងបទល្មើសនៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពិសេសលើស្ត្រីនិងកុមារ ក្នុងគោលបំណងប្រយុទ្ធប្រឆាំងនិងទប់ស្កាត់អំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ឲ្យមានប្រសិទ្ធភាពខ្ពស់ ។ សហការ និង ចាត់វិធានការឲ្យទាន់ពេលវេលាក្នុងការបង្ក្រាបបទល្មើសទាំងនេះ និងធ្វើអន្តរាគមន៍ជួយសង្គ្រោះជនរងគ្រោះ ។

**មាត្រា២ ៖** អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវសហការជាមួយសមត្ថកិច្ចនគរបាលជាតិកម្ពុជាក្នុងការស៊ើបអង្កេត និង ប្រមូលភស្តុតាងនានាពាក់ព័ន្ធអំពើជួញដូរមនុស្ស ផ្ទះបន និង ទីកន្លែង

ផ្សេងទៀតដែលស្ត្រីនិងកុមារត្រូវបានគេជួញដូរ និងបង្ខាំងទុកធ្វើអាជីវកម្មផ្លូវភេទ ។ ក្រោយប្រមូលបានភស្តុតាងស្របតាមនីតិវិធីច្បាប់និងគ្រប់ជ្រុងជ្រោយ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវផ្តល់ភស្តុតាងទាំងនោះ ទៅសមត្ថកិច្ចនគរបាលជាតិកម្ពុជា ជាពិសេសអង្គភាពប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជនជាបន្ទាន់ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។ ក្នុងពេលប្រតិបត្តិការស៊ើបអង្កេត អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវសហការជាមួយកម្លាំងមានសមត្ថកិច្ច និងប្រកាន់ខ្ជាប់ទៅតាមអនុស្សរណៈនៃការយោគយល់គ្នានេះ ។

**មាត្រា៣ ៖** ឧបករណ៍ដែលបានយកទៅប្រើប្រាស់ក្នុងពេលប្រមូលព័ត៌មាន និង ភស្តុតាងពាក់ព័ន្ធអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទនៃ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវមានការឯកភាពពីក្រសួងមហាផ្ទៃ ។

**មាត្រា៤ ៖** មន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងអង្គភាពមន្ត្រីនគរបាលមានសមត្ថកិច្ចផ្សេងទៀតសហការជាមួយ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ដើម្បីផ្តល់ព័ត៌មាន និងភស្តុតាងឲ្យគ្នាទៅវិញទៅមក ដើម្បីឈានទៅបង្ក្រាបបទល្មើស និងឃាត់ខ្លួនជនសង្ស័យឲ្យបានទាន់ពេលវេលា ។

**មាត្រា៥ ៖** ក្នុងករណីចាំបាច់និងមានតម្រូវការពីក្រសួងមហាផ្ទៃ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ធ្វើការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជំនាញនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ព្រមទាំងអង្គភាពប្រឆាំងការជួញដូរមនុស្ស និងមន្ត្រីនគរបាលពាក់ព័ន្ធ ។ ការបណ្តុះបណ្តាលរួមមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះ និងច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

## ផ្នែកទី៣
## ភារកិច្ចរបស់ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ មានភារកិច្ចដូចខាងក្រោម ៖

**មាត្រា៦ ៖** អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិត្រូវគោរពឲ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និង មិនអនុញ្ញាតឲ្យភ្នាក់ងាររបស់ខ្លួន មានការចូលរួមក្នុងសកម្មភាពណាមួយដែលអាចធ្វើឲ្យប៉ះពាល់ដល់សន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សង្គម ឬក៏សកម្មភាពដទៃទៀត ដែលអាចបង្កអន្តរាយ ដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា ។

**មាត្រា៧ ៖** អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវប្រតិបត្តិរាល់សកម្មភាព និង អនុវត្តកម្មវិធីមនុស្សធម៌នៅប្រទេសកម្ពុជាក្នុងក្របខណ្ឌនៃធនធានបុគ្គលិក និងមូលនិធិរបស់ខ្លួនព្រមទាំងធានាឲ្យបានថារាល់ការទទួលបានភស្តុតាងនៃការបំពានច្បាប់កម្ពុជា ដែលខ្លួនបានប្រមូល នឹងត្រូវបញ្ជូនទៅនគរបាលមានសមត្ថកិច្ចសម្រាប់ចាត់វិធានការបន្ត ។ រាល់ការចុះស៊ើបអង្កេតត្រូវផ្តល់ព័ត៌មាន

មកអង្គភាពជំនាញប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន ។ រាល់នីតិវិធីនៃការស៊ើបអង្កេតសម្ងាត់ ត្រូវមានការឯកភាពគ្នារវាងភាគីទាំងពីរមុនពេលអនុវត្ត ។

**មាត្រា៨ ៖** អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ចូលរួមតែក្នុងសកម្មភាពមនុស្សធម៌ ដែលទទួលបានការអនុញ្ញាតពីក្រសួងមហាផ្ទៃ ដើម្បីសុខុមាលភាពសង្គម និងប្រយោជន៍សាធារណៈ ។ ជៀសវាងដាច់ខាតពីការពាក់ព័ន្ធនឹងសកម្មភាពបង្កើតប្រាក់ចំណូល និង ប្រាក់ចំណេញ និងសកម្មភាពនយោបាយដែលមិនបម្រើដល់គោលដៅមនុស្សធម៌ និងអភិវឌ្ឍន៍សង្គមរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិដែលបានប្រកាស ។

## ជំពូកទី៤
## អវសានបញ្ញត្តិ

**មាត្រា៩ ៖** រាល់វិវាទរវាង ក្រសួងមហាផ្ទៃ និង អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ដែលទាក់ទងនឹងការអនុវត្ត ឬ ការបកស្រាយអនុស្សរណៈនេះ នឹងត្រូវបានដោះស្រាយតាមរយៈការចរចាដោយសន្តិវិធីរវាងភាគីទាំងពីរ ។

**មាត្រា១០ ៖** អនុស្សរណៈនៃការយោគយល់គ្នានេះអាចត្រូវបានបញ្ឈប់ដោយភាគីណាមួយក៏បាន គឺបន្ទាប់ពី៦០ថ្ងៃដែលភាគីនោះផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបញ្ជូនទៅភាគីម្ខាងទៀត ។

**មាត្រា១១ ៖** អនុស្សរណៈនេះចូលជាធរមាននៅពេលដែលភាគីទាំងពីរចុះហត្ថលេខា និង មានសុពលភាពរយៈពេល០៣ ឆ្នាំ ហើយនឹងត្រូវបន្តសុពលភាព ដោយមានការយល់ព្រមទាំងសងខាង ។

**មាត្រា១២ ៖** អនុស្សរណៈនេះធ្វើឡើងជាពីរច្បាប់ ជាភាសាខ្មែរមួយច្បាប់ និង ភាសាអង់គ្លេសមួយច្បាប់ ។ អត្ថបទទាំងពីរនេះមានតម្លៃស្មើគ្នាតាមផ្លូវច្បាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី 8 ខែ Oct. ឆ្នាំ 2013

**ក្រសួងមហាផ្ទៃ**

ឯកឧត្តមនាយឧត្តមសេនីយ៍ **តេង សាវង្ស**
រដ្ឋលេខាធិការ

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ**

Christa Sharpe

លោកស្រី **គ្រីស្ដា ហ្សាប**
នាយិកា